គេមិនចែករំលែករឿងរ៉ាវគេជាមួយឯងទេអាគីម៉ាល់។

បុរសគិតហើយងាកមុខសម្លឹងទន្លេ គេមិនឆ្លើយតបនឹងនាងឡើយ។

ស្រីស្អាតញញឹមតិចតួចមុនពេលបែរខ្នងចូលទៅខាងក្នុងអង្គុយកន្លែងរបស់នាងដដែល។ ជារឿយៗ បុរសក្រឡេកទៅឃើញនាងធ្មេចភ្នែក ។

តាមពិតនាងមិនបានគេងទេ ក៏មិនងងុយប៉ុន្តែ ហាន់ជាសែនហត់ចិត្ត។ ការសន្ទនាមុននេះនៅតែតាមមករំខាននាង៖

«សុងសក្តិ ខ្ញុំឡើងទូកខុស!»

«ម៉េចអ៊ីចឹង? នីដាកុំកុហកណ៎ា នីដាប្រាប់ទីតាំងមក នៅឯណា?!»

«ខ្ញុំកុហកធ្វើអី! ខ្ញុំជិតដល់ក្រចេះហើយ!»

«ទូរសព្ទនីដាខលមិនចូលទេ ខ្ញុំទាក់ទងមួយព្រឹកហើយ!»

«មកពីនៅលើទឹកទេដឹងសុងសក្តិ!»

«នីដាឆាប់ប្រាប់ទីតាំងមក! ហើយនៅជាមួយអ្នកណា គ្រប់គ្នាកំពុងបារម្ភ!»

នាងធ្មេចភ្នែក។

ហេតុអ្វីចុងក្រោយយើងនៅតែជាប្រធានបទឱ្យគ្រប់គ្នាបារម្ភ។ ប៉ុន្មានលើកទៅ ដែលយើងគួរតែនិយាយគ្នាច្បាស់ៗនឹងសុងសក្តិថា ទោះបីពិសិដ្ឋស្លាប់ តែយើងនឹងមិនមានអីជាមួយគេទេ ក្រៅពីការរាប់អានទុកចិត្ត គឺស្នេហាមិនអាចកើតមានឡើងឡើយ។

យូរប៉ុនណាហើយដែលឯងលែងចេះស្រលាញ់មនុស្សប្រុស? យូរប៉ុនណាហើយដែលមនុស្សល្អៗត្រូវបាន ឯងមានអារម្មណ៍សាបឈឹង មិនត្រេកត្រអាល មិនស្រើបស្រាលជាមួយ?

យូរប៉ុនណាហើយដែលបេះដូងឯងមិនដែលលោតច្របល់ដូចកាលឃើញនាយម្ចាស់ទូកម្នាក់នេះ?

នាងបើកភ្នែកព្រឹមៗ ដៀងសម្លឹងទៅកន្លែងអាហារដែលបានចរចាមុននេះ។

ប្រុសស្អាតលែងមានវត្តមានហើយ ។ គេទៅណាបាត់ក៏មិនដឹង។ ណ្ហើយចុះ! បន្តិចទៀត គឺលែងបានឃើញគេដដែលជាដដែល ឯងក៏មានរឿងច្រើនរ៉េកទូលមិនចង់អស់ ឯងចង់បន្ថែមអម្រែកមួយទៀតឬយ៉ាងម៉េច។

នាងប្រុងបិទភ្នែកវិញ ស្រាប់សំឡេងមួយលាន់មកពីក្រោយខ្នង៖

«ទូកនេះ មានកន្លែងអាចសម្រាកបាន!»

ហាន់ដាបើកភ្នែកឡើងមកវិញខ្វាក។ បុរសនេះពិតជាស្រមោលអន្ទោលតាមប្រាណពិតមែន។ មួយផ្លេចពីរផ្លេចសោះ គេក៏មកដល់ពីក្រោយខ្នងយើងទៅហើយ។

មិញនេះយើងមានបានច្រឡំនិយាយអ្វីក្នុងចិត្តចេញមកឱ្យឮដល់គេដែរអត់ទេ?

នាងគិតទាំងបារម្ភភឹប។

សំឡេងគេលាន់មកបន្ថែម៖

«អាចសម្រាកក្នុងបន្ទប់បាន!»

នាងគ្រវីក្បាលសឹងលឿនជាងគេនិយាយចប់ទៅទៀត។

សំឡេងបុរសលាន់មកផ្ទួនៗ៖

«កុំច្រឡំ! ម្នាក់នេះមិនមែនព្រាននារីហើយក៏មិនកេងចំណេញលើអ្នកណាដែរ!»

នាងបែរក្រោយឃើតៗ ។

ទឹកមុខគេមិនបានក្រៀមស្រពោនដូចសព្ទសំឡេងទេ។

គេសម្លឹងនាងជាមួយកែវភ្នែកឱ្យដងដដែលជាដដែល។

«គីម៉ាល់ គ្មានអ្នកណាគិតអ្វីអាក្រក់ៗដូចដែលនិយាយមិញនេះទេ!»

«បើអ៊ីចឹងចូលទៅសម្រាកទៅ!»

«ជិតដល់ហើយ! ខ្ញុំគ្រាន់តែសម្រាកភ្នែក តែខ្ញុំមិនងងុយទេ!»

គីម៉ាល់រេភ្នែកសម្លឹងដងទន្លេចំពោះមុខនិងច្រាំងបៃតងញឹក ដែលបង្អួសជាជួរវែងឆ្ងាយដាច់កន្ទុយភ្នែក ។

«ខ្ញុំចុះនៅខេត្តក្រចេះនេះ!»

នាងពោលបន្ថែម។

ខាងប្រុសនៅស្ងៀម ព្រោះដល់វេនគេផ្ចេចភ្នែកម្ដង។ គេកំពុងរំងាប់ចិត្ត ហើយតតាំងរវាងគំនិតពីរ គឺតាមនាងឡើងទៅ ឬមួយក៏បំភ្លេចនាងចោលត្រឹមណេះ?

សារជាថ្មីទូរសព្ទនាងរោទ៍។

ទោះបីធ្មេចភ្នែកទាំងសងបុរសនៅតែសម្គាល់ដឹងថានាងក្រោកចេញទៅស្រាលៗ ដើម្បីនិយាយទូរសព្ទនៅខាងក្រៅវិញ។

សម្រិបជើងថ្មីទៀត លាន់ឡើងមកផ្តាច់ចង្វាក់តាមដានស្តាប់របស់គេ។

គីម៉ាល់បើកភ្នែកសន្សឹមៗសម្លឹងអ៊ុនដែលមកដល់ក្បែរជាមួយទឹកមុខស្លេក។

មានអ្វីមួយមិនល្អ បម្រុងកើតមានកណ្តាលទន្លេនេះ?

គេដាក់សំណួរចេញតាមរយៈពន្លឺភ្នែកដែលដៀងទៅរង់ចាំស្តាប់មនុស្សជំនិតរាយការណ៍។

«បងគីម៉ាល់! មើលនៀក!» អ៊ុនខ្សឹបៗ។

គីម៉ាល់វេភ្នែកចោលទឹកមុខស្លេកស្លាំងរបស់កូនចៅហើយផ្តោតមកលើអេក្រង់ទូរសព្ទវិញម្តង។ អ្វីមួយចាក់ភឹបចំបេះដូងនាយ។

វាដូចជាអាវុធ ត្រជាក់ក៏ថាបាន ក្តៅក៏ថាបាន តែយ៉ាងណាមិនថារលោកឬមុតទេ វាឈឺដោយគ្មានមូលហេតុ។

គេមិនចាប់អារម្មណ៍នឹងរូបពិសិដ្ឋប្អូនគេទេ តែគេសម្លឹងនារីដែលកំពុងរៀបការជាប្អូនថ្លៃខ្លួនក្នុងរូបថត។ ប្រុសស្អាតច្រត់កែងដៃយោងខ្លួនក្រោកសន្សឹមៗពីការទម្រេត ហើយចុងក្រោយនាយដៀងភ្នែកសម្លឹងទៅមនុស្សស្រីរូបពិត ដែលឈរបែរខ្នងនិយាយទូរសព្ទសក់បោកបក់រវិចតាមកម្លាំងវាយោ។

ស្នូរជើងមនុស្សរត់ចូលមកដល់ថែមទៀត។

អ៊ុនងាកទៅរកវុធដែលត្របាបជាមួយភាពសង្ស័យ។ ចៅហ្វាយប្រុសមិនទាន់ដកភ្នែកចេញពីស្រីស្អាតដែលឈរបែរខ្នងនៅឡើយផង គេរាយការណ៍ខ្សឹបខ្សៀវ៖

«បង! ទូកពួយឹមមកដល់កៀកយើងហើយ!»

គីម៉ាល់ចងចិញ្ចើម រុញទូរសព្ទត្រឡប់ទៅសងអ៊ុនហើយក្រោករឹងអើតសម្លឹងទៅក្រៅតាមបង្អួច។ កូនទូកទំនើបមួយពិតជាកំពុងជ្រែកទឹកសំដៅមក។

«គេប្រហែលដឹងថា ប្រពន្ធបងសិដ្ឋនៅលើទូកនេះតែមិនទាន់ដឹងថា ជាទូកបងគីម៉ាល់ទេ!»

អ៊ុនឆ្លៀតឱ្យយោបល់ ធ្វើឱ្យគីម៉ាល់បែរក្រោយមកសម្លឹងកូនចៅ។

«មើលម៉េចដឹងថាទូកតាយឹម?»

«គ្នាយើងឆ្លុះឃើញបង!»

ក្រៅពីឆ្លើយតបហើយវុធឆ្លៀតឱកាសសួរបញ្ជាក់ភ្លាម៖

«បង! យើងទៅមុខគេចចេញ ឬមួយធ្វើមិនដឹង?!»

គីម៉ាល់នៅស្ងៀមមិនទាន់ឆ្លើយស្រាប់តែអ៊ុនបន្ទោស៖

«ពួកនោះចង់បានប្រពន្ធបងសិដ្ឋទៅ! យើងធ្វើមិនដឹងដូចមិនកើតទេដឹង?!»

សារជាថ្មី គីម៉ាល់ងើបមុខសម្លឹងទៅស្រីស្អាត។

ដំណឹងដែលថានាងជាប្អូនថ្លៃរបស់ខ្លួនកំពុងសង្កត់បេះដូងនាយទៅហើយចុះទម្រាំពេលនេះ ប្រសិនដំណឹងតាមសម្លាប់នាងជាការពិតវិញ តើអ្វីទៅជាដំណោះស្រាយស័ក្តិសមក្នុងពេលវេលានេះ?

«ខ្ញុំចុះនៅខេត្តក្រចេះនេះ!»

សម្តីនាងទើបតែប្រាប់គេរំឭកឡើងមកវិញក្នុងការពិចារណាវិលខ្វាល់។

គេសម្លឹងសងខាង ទៅរកសរសៃច្រាំងតូចឆ្មារដែលនៅឆ្ងាយសន្លឹម។ ទន្លេនេះត្បិតតែធំ តែធំយ៉ាងណា ឆ្ងាយយ៉ាងណា នាងជិតដល់ទីសំចត  ជិតដល់ដីគោកហើយ។  បើនាងចុះមែន ហើយបើដំណឹងដែលថាខាងណោះតាមសម្លាប់នាងក្លាយជាការពិត គ្រោះថ្នាក់នេះបញ្ចៀសម្តេចបាន។

តើនាងបានឆ្លោយប្រាប់ពីវត្តមានខ្លួនលើដែនទឹកតំបន់នេះ ដល់មនុស្សមិនល្អណាម្នាក់ឬអ្វី ? ឬមួយទូរសព្ទនាង ក្រោយពេលមានសេវាឡើងវិញត្រូវបានគេចាប់សញ្ញា GPS ហើយទើបក្រុមមនុស្សអាក្រក់អាចតាមនាងមកដល់ទីនេះបាន?

ទូកទំនើបបោលកាន់តែកៀក គេខ្សឹបទៅរកមនុស្សជំនិតដែលកំពុងត្រងស្តាប់៖

«បើពួកនោះចង់ឡើង! ឱ្យឡើងមក! ខាងយើងមានល្ខោនកំដរ»

គេគិតយ៉ាងរវៀសរវៃ ស្របពេលដែលនារីតូចនៅខាងក្រៅស្រាប់តែបែរមកវិញ។ តរុណីដើរមួយៗសំដៅមកក្នុងទំនងតម្រង់ទីដាក់វ៉ាលិស។

សភាពរបស់នាងគឺចង់ចុះកណ្តាលទី មិនទៅដល់គោលដៅចុងក្រោយគឺស្ទឹងត្រែងនោះទេ។

ដំបូងនាងដើរលឿនធម្មតា លុះឃើញបុរសទាំងបីសម្លឹងមកខ្លួនយ៉ាងចម្លែក នាងចាប់ផ្ដើមបន្ថយល្បឿន។

គីម៉ាល់និយាយតិចៗទៅកាន់អ៊ុននិងវុធ៖

«ចាប់ស្រីនេះចូលបន្ទប់!»

នាងជារបស់ខ្ញុំ

នៅមិននៅហាន់ជាត្រូវបានបង្ខំនាំចូលទៅក្នុងកូនបន្ទប់តូចមួយ ដែលជាកម្មសិទ្ធិនៃម្ចាស់ប្រុសរបស់ទូកនេះ។

មិនស្មានថាពេលជិតមកដល់ទីដៅ នាងបែរជាត្រូវបានគេធ្វើបំពានដល់ថ្នាក់នេះ មិនឱ្យស្រីល្អស្រទ្បាំងកាំងម្ដេចនឹងបាន?

ពីក្រោយខ្នងវុធនិងអ៊ុន គីម៉ាល់បង្ហាញខ្លួនជាមួយទឹកមុខចម្លែក។

ម្ដងនេះមានសុទិដ្ឋិនិយមបែបណាក៏នាងមើលមិនឃើញថាគេជាសុភាពបុរសដូចកាលពីព្រឹកទៀតនោះដែរ។

ចំមែនហើយ! នៅមិននៅចុះចំទូកពួកចោរ ហើយច្រលំនិយាយល្អៗនឹងមេចោរអស់ពេញមួយព្រឹក។ នាងខឹងណាស់តែមិនបាននិយាយអ្វីចេញនៅឡើយព្រោះតែអារម្មណ៍រន្ធត់។ ពេលអ៊ុននិងវុធដកថយចេញ ហាន់ជាប្រញាប់ប្រញាល់ស្ទុះទៅតាមជាមួយពួកគេដែរ តែត្រូវប្រុសម្ចាស់បន្ទប់ទាញដៃត្រឡប់មកវិញ។

កែងជើងគេរុញទ្វារបន្ទប់បិទទៅវិញស្រឹបព្រោះជាប្រភេទទ្វារដែកស្រាលស្ញើក។

«ហេតុអី!»

នាងសួរឡើងទាំងសំឡេងញ័រៗ។ នារីនេះមិនដឹងថា នាយជាអ្នកណាទេតែនាងកំពុងមមៃនឹកថាអ្វីទៅដែលនឹងកើតមានចំពោះខ្លួន។

«ពាក្យនេះ ខ្ញុំជាអ្នកត្រូវសួរ!»

គេឆ្លើយជាមួយទឹកមុខសៅហ្មង។

នៅមិននៅ មនុស្សស្រីដែលគេគិតថាទាក់ទាញបំផុតម្នាក់ ក្លាយមកជាប្អូនថ្លៃ។ អារម្មណ៍ច្របូកច្របល់មួយគ្រានេះ ធ្វើឱ្យចិត្តខាងប្រុសទៅជាច្រងាប់ច្រងិល។ ប្រសិននាងជាស្រីមានប្ដីទើបនឹង

ស្លាប់ប្រមាណមិនដល់ពីខែត្រឹមត្រូវផង នាងហ៊ានមកអង្គុយញញឹមឌឺដងជាមួយប្រុសផ្សេងលើទូកតែពីរនាក់បែបនេះ ស្លៀកពាក់ស្រស់បំព្រងបែបនេះដោយរបៀបណា?

គេដៀងសម្លឹងនាងពីលើដល់ក្រោម។

នារីនេះកំពុងក្តាប់ម្រាមទាំង១០ចូលគ្នាសម្លឹងមកខ្លួនម៉ក់ៗ ។

សកម្មភាពនាង គឺប្រុងជើងការដោះស្រាយជាមួយនាយគ្រប់វិនាទីប្រសិននាយបញ្ចេញកាយវិការណាមួយ។ នាងមិនដឹងឡើយថា ចំណោទជាច្រើនកំពុងតែពុះព្រៃកចិត្តខាងប្រុស។

ចិត្តមួយគេនឹកស្តាយ ដែលស្រីស្អាតទើបនឹងជួបគ្នាមិនបានប៉ុន្មាន ក្លាយមកជាប្អូនថ្លៃគឺជាមនុស្សជាទីស្រឡាញ់នៃប្អូនប្រុសសំណព្វ ចំណែក ចិត្តមួយទៀតខឹងថា ហេតុអ្វីនាងមានស្នេហ៍រោលរាលដាក់មនុស្សប្រុសកម្រិតនេះ?

«ខ្ញុំអត់យល់ទេគីម៉ាល់!»

នាងប្រឹងនិយាយមួយៗ ទប់ស្កាត់ភាពភ័យខ្លាចចំពោះកែវភ្នែកទុក្ខសោករបស់គេ។ បុរសនេះផ្លាស់ប្តូរចរិតលឿនពេក ថ្នាក់នាងភ្លេចអស់រលីងភាពកក់ក្តៅដែលគេបានផ្តល់មកកាលពីព្រឹក។

«មនុស្សស្រីធុនណា មកនៅជាមួយមនុស្សប្រុសមួយទូក ហើយឥឡូវមកធ្វើញញើតធ្វើអី?!»

ខាងប្រុសវាចាតិចៗ ទាំងសម្លឹងនាងផ្តោតដល់ប្រស្រីភ្នែកដែលខ្មៅរលើប។ ព្រឹកមិញគេមិនបាននិយាយរបៀបអ៊ីចឹងទេ! នាងចាប់ផ្តើមវិលវល់។ អ្វីទៅបានជាធ្វើឱ្យសំឡេងរបស់ គេក្លាយទៅជាគួរឱ្យស្អប់ខ្ពើមនិងហួសចិត្តដល់ថ្នាក់នេះ។

ជាមួយការតូចចិត្តចំពោះសំណាងមិនល្អរបស់ខ្លួន ព្រមជាមួយការខឹងចិត្តនូវពាក្យសម្តីមិនគប្បីរបស់នាយ ខាងស្រីប្រញាប់តបតវិញទាំងញ័រមាត់៖

«កោតតែខ្ញុំមើលមនុស្សខុស!»

ពោលចប់ រោមចិញ្ចើមទាំងសងរបស់នាងក្រញូវឡើងដោយកំហឹង។

ទំនងជាស្រីស្រស់កំពុងខឹងខ្លួនឯងដែលប្រហែសខ្លាំងនាំឱ្យស្តាយក្រោយពន់ពេក ហើយក៏ទំនងជាខឹងនិងស្តាយរូបភាពប្រុសស្អាតដែលបានចូលមកស្ពំបេះដូងពេញមួយព្រឹកមកហើយនោះដែរ។

ឮនាងមានប្រតិកម្មតបត គេស្រាប់តែលែងនិយាយបែរជាដើរចូលមកក្បែរ។ ចិត្តរបស់ហាន់ដាចាប់ផ្តើមច្របល់ជាមួយដំណើរដើរឆ្ពោះមករកនាង ហើយមាត់របស់គេចំហឌឺដង លែងនិយាយលែងស្តី។

ស្នូរទូរសព្ទនាងរោទ៍ នាងហាក់ត្រេកអរ...តែវាត្រូវបានរបូតពីប្រអប់ដៃ ធ្លាក់ទៅក្នុងហត្ថាប្រុសស្អាតទៅវិញ។

គេសម្លឹងនាងមួយខ្ទាច់មុនពេលដៀងទៅរកអេក្រង់។

មនុស្សប្រុសដដែលៗនោះបង្ហាញវត្តមានរកនាងជាថ្មី តែម្តងនេះមិនបានធ្វើឱ្យគេត្រជាក់ចិត្តអត់ធ្មត់បានដូចកាលពីនៅខាងក្រៅទៀតទេ។

ទឹកមុខនាងដែលហាក់មានអំណរពេលឮសព្ទសំឡេងរោទ៍ បានដុតបំពក់ភ្នក់ភ្លើងប្រចណ្ឌក្នុងទ្រូងគីម៉ាល់។

មិនចាំបាច់បែងចែកថា គេហួងហែងក្នុងនាមបងថ្លៃឬក្នុងនាមអ្វីទេ ដឹងតែថាខលមកមិនត្រូវពេលតែម្តង។

«ខលៗ សម្បូរប្រុសខលណាស់យើងហ្នឹង!»

គេគិតទាំងក្នាញ់ក្នុងចិត្តជាពន់ពេកតែមិននិយាយចេញជាសំឡេងនៅឡើយ គ្រាន់តែសម្តែងចេញតាមកែវភ្នែកស្រឹមល្ហល្ហេវសម្លក់នាង។

«គិតចង់ចុះនៅក្រចេះជួបអាម្នាក់ហ្នឹងហ្មែន?!»

គីម៉ាល់ខាំមាត់និយាយរអ៊ូសួរតិចៗ ហើយបោះវាចោលទៅក្រោយខ្នងធ្លាក់ខ្ទាកលើកម្រាលដែកលាន់ឆឹង។

នារីបើកភ្នែកធំៗចំពោះកាយវិការនៃមនុស្សរាកម្រោលនេះ។

គេហ៊ានពេកហើយ!

ទូរសព្ទនៅតែបន្តរោទ៍កំដរកំហឹងខាងប្រុសនិង ភាពតក្កមារបស់ខាងស្រី។ ទោះយ៉ាងណានាងដឹងថាគេនេះខ្មោចចូលហើយ មិនមែនគីម៉ាល់កាលពីព្រឹកទេ។ នាងរកវិធីដោះខ្លួន៖

«គីម៉ាល់! ឱ្យខ្ញុំទៅៗ ខ្ញុំអត់បានធ្វើអីមិនល្អទេ!»

កំហឹងរបស់គេហាក់រសាយ ពេលឃើញនាងលើកដៃទាំងទ្វេមកសំពះ ។ យូរណាស់មកហើយ គេមិនដែលបានឃើញការសំពះគួរឱ្យទន់ចិត្តពីនារីខ្មែរណាម្នាក់ឡើយដោយសារគេមិនដែលវិលមកស្រុកខ្មែរ។

ភាពតក់ស្លុតរបស់នាង បានបណ្ដាលឱ្យគេដឹងខ្លួនបន្តិចម្ដងៗពីកំហុសឆ្គាំឆ្គងដែលកំពុងអនុវត្តដោយគ្មានមូលហេតុច្បាស់លាស់។

គេលូកដៃតម្រង់មករកថ្ពាល់ភ្លឺរលោង ក្រហមឡើងៗ ព្រោះទោសៈ។ នាងធ្មេចភ្នែកគេចចេញពីដៃគេជាមួយពាក្យបដិសេធភ្លាមៗ៖

«កុំប៉ះខ្ញុំអី! មិញនៅខាងក្រៅ គីម៉ាល់និយាយហើយថា មិនមែនជាព្រាននារីហើយក៏មិនកេងចំណេញលើអ្នកណាដែរ!»

ប្រុសស្អាតក៏បង្អង់ដៃ មុនពេលទម្លាក់ចុះយឺតៗហើយក៏ចាប់ផ្ដើមសើចខ្លាំងៗ។ គេសើចរហូតដល់នាងបើកភ្នែកមកវិញ។

គេទុកនាងដូចជារឿងកំប្លែងពិតណាស់។

ហាន់ដារលើងរលោងចំពោះមុខមនុស្សដែលកំពុងយកនាងជាគ្រឿងលេងសើច ។ ជលនេត្រាថ្លាឆ្វង់ដក់នៅទីនោះ ដក់នៅកែវភ្នែកទាំងគូដែលកាលពីព្រឹកភាន់ភាំងពេលឃើញគេដំបូង ពេលនេះបានធ្វើឱ្យគេស្រងេះស្រងោច ក្នុងចិត្តអាណិតទឹកភ្នែកនាង......

បបូរមាត់ខាងប្រុស ធ្លាប់តែសិចស៊ីទៅដោយស្នាមសើចចំអកព្រហ្មលិខិត ពេលនេះប្រែទៅជាស្លេកស្មើ នឹងលែងរង្គើលែងស្រដី មើលមកនាងដូចជា...ហឹម! រាងពិបាកនិយាយ មិនថា ចង់លេបនាងទុក ឬចង់ខាំត្របាក់ដូចខ្លាឃើញម្រឹគ ដូចរាហ៊ូឃើញចន្ទ គឺគ្រប់យ៉ាងទាំងព្រមក្នុងពេលតែមួយ។

ខាងស្រីវិញដែលឃើញទឹកមុខគេពេលនេះ មិនដឹងថាគួរសប្បាយ គួរភ័យ ឬគួរធ្វើអ្វីនោះទេ ព្រោះអាក្រក់និងល្អ សុទ្ធតែអាចកើតមានឡើងបានក្នុងវិនាទីតែមួយ។

ឃើញនាងនៅញាប់ញ័រយ៉ាងខ្លាំង ក្នុងភាពអស់សង្ឃឹមសម្លឹងមកខ្លួនហាក់ចង់សុំក្ដីករុណា ស្នាមញញឹមសម្ងាត់លេចចេញតាមពន្លឺកែវភ្នែកបុរសទាំងសង ដូចជាបង្ហាញពីជ័យជម្នះនិងការគ្រប់គ្រងឯកសិទ្ធិ។

គេអាងអីទៅ?

នាងមានៈរើបម្រះ គេកាន់តែបង្កើនកម្លាំងចោមព័ទ្ធ។ អ្ហុះ! ភ្លេចខ្លួន ដៃគេទាំងសងបានឱនត្រកងឱបនាងតាំងពីពេលណាមករហូតដល់នាងច្រានចេញមិនរបើក ក្ដិចខ្ទាំមិនរង្គើ ទើបនាងស្រែកហៅឈ្មោះនាយ៖

«គីម៉ាល់!»

នាងហៅគេខ្សាវៗ ផុតៗ ទៅតាមភាពរំជួលនៃបេះដូង។ គ្មាននារីណាត្រៀមចិត្តរួចរាល់ក្នុងការប្រគល់ខ្លួនជាចំណីនាយសូម្បីតែទើបស្គាល់គ្នាជាងកន្លះថ្ងៃនោះទេ។ គេក៏គួរយល់ដែរថាគេកំពុងតែឈានលើសគំនូសព្រំដែនហើយ។

ទោះយ៉ាងណា កាលដែលនាងនៅចាំឈ្មោះគេហៅគេបានពីរម៉ាត់យ៉ាងផ្អែមនោះ ធ្វើឱ្យបេះដូងគេរង្គោះ។

«ហាន់ដា!»

គេហៅនាងតបវិញស្រាលៗ បង្ហាញថា គេមិនបានបន្ថយចំណង់តណ្ហា សម្ដីនាងមិនបានទាញគេវិលមកសម្បជញ្ញៈវិញ អ្វីសូម្បីបន្តិចណាឡើយ។

«កុំធ្វើអ៊ីចឹង! ខ្ញុំចង់និយាយថា...»

នាងមានសម្ពាធដល់ថ្នាក់សំឡេងក្លាយជាខ្សឹបខ្សៀវ ខាងប្រុសកាន់តែយល់ខុស។ មោទនភាពលើខ្លួនឯង មានប្រសិទ្ធិភាពធ្វើឱ្យគីម៉ាល់លង់ក្នុងភាពស្រើបស្រាល ចំណែកសកម្មភាពរញ៉េរញ៉ៃតិចៗរបស់នាងរឹងរឹតតែបង្កាត់ភ្លើងស្នេហ៍សន្ធោសន្ធៅកម្ដៅទ្រូងអ្នកប្រុស។

នារីនេះកំពុងមានៈការពារខ្លួនតាមធម្មជាតិនារីភេទ ក៏កំពុងច្របូកចិត្តច្រណែនប្រចណ្ឌ ឬអាចថាកំពុងមានអារម្មណ៍ប្រឆាំងគ្នាច្រើនយ៉ាងក្នុងពេលតែមួយ។

ដៃនាងត្រូវគេចាប់  ម្រាមទាំងដប់ ត្រូវបានគេគ្រង។

ហាន់ដាដកដង្ហើមវែងៗ ដូចជាវត្តមានរបស់គេនៅទីនេះកំពុងព្យាយាមធ្វើឱ្យអុកស៊ីសែនរបស់នាងបាត់បង់ទៅសឹងតែបន្តិចទៀតអាចគាំងចលនាបេះដូងបាន។

ដោយអត់ធ្មត់នាងនិយាយស្រាលៗតបវិញ៖

«បើគីម៉ាល់មិនធ្វើដៃដល់ មិនបង្ខំចិត្ត ថ្ងៃណាមួយហាន់ដាអាចនឹងថើបគីម៉ាល់ដោយខ្លួនឯង!»

ថាចប់ នាងក្រហមថ្ពាល់ខ្លាំងឡើងៗក្រោមស្នាមញញឹមពេញចិត្តនៃប្រុសស្អាត។ ភ្នែកគេមើលនារីនេះមិនចេះហត់ មិនចេះនឿយ មិនចេះធុញ។ ស្រីខ្មែរ ពិតជាបង្ករសអារម្មណ៍ ស្អិតល្មួតលំដាប់ពិសេសជ្រាលជ្រៅពិបាកនិយាយឱ្យនិយមន័យតែគីម៉ាល់ពិតណាស់ មិនដែលស្គាល់រសនេះជាយូរមកហើយ។

«ខ្ជិលចាំណាស់! មនុស្សនេះមិនចេះរង់ចាំទេ ស្អប់ណាស់ការរង់ចាំ!»

គេរអ៊ូខ្សឹបខ្សៀវដាក់សោតាស្រី។ គីម៉ាល់មិនមែន ជាមនុស្សនិយាយច្រើនតែជួនកាល ស្នេហាពិតជាមានអនុភាពអាចបង្ខំគេ ធ្វើឱ្យគេចេះ នូវរឿងដែលគេមិនធ្លាប់ចេះ។ នារីចំពោះមុខជាស្រីមានប្ដីរួចហើយម្ដេចនាង នៅតែមានមន្តស្នេហ៍ម្លឹងៗហេតុអ្វីយើងមិនមាននិស្ស័យបានជួបគេតាំងពីដំបូងមក?

«បងស័កសន្យានឹងខ្ញុំ! ត្រូវមើលថែគេ! ប្រពន្ធខ្ញុំជាមនុស្សល្អ! ត្រូវថែរក្សាគេ ថ្នាក់ថ្នមគេពេញមួយជីវិតនេះជំនួសប្អូន!»

គេចង់រំឭកបណ្ដាំនេះពេញបេះដូង ថែមទាំងចង់និយាយប្រាប់នាងត្រង់ៗ តែគេមិនហារចេញរឿងនេះដោយនិយាយពាក្យផ្សេងជំនួស៖

«ដាជារបស់ខ្ញុំ! ដាជារបស់អាម្នាក់នេះ! កុំសង្ឃឹមរឿងចាកចេញ កុំសង្ឃឹមកែប្រែរឿងមួយនេះ! ឮ?»

គេលែងដៃនាងសន្សឹមៗ ពេលខាងស្រីកំពុងភាន់ភាំង។

បុរសនិយាយបន្ថែមដោយច្បាស់លាស់គត់មត់៖

«កុំឱ្យសោះរឿងគិតចង់រត់ ទោះទៅដល់ជើងមេឃណាក៏នៅតែត្រូវត្រឡប់មកវិញដែរ!»

នាងនៅស្ងៀមព្រោះនាងដឹងរឿងមួយ។